ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ: ៤៤ ក.យ.ប្រ.ក/០៩

# ប្រកាស
# ស្តីពីការកែសម្រួល
# ឧបសម្ព័ន្ធ ១ និង ឧបសម្ព័ន្ធ ៤
# នៃប្រកាសលេខ ២៨ កយ ប្រក,០៧ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធ ដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និង មាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រជាប់ក្តីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨.១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ២៨ កយប្រក.០៧ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រជាប់ក្តីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង
- យោងតាមមាត្រា ៦០, មាត្រា ៦១, មាត្រា ៦២, និង មាត្រា ៣៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- យោងតាមភាពចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## សម្រេច

**ប្រការ ១**: ត្រូវបានកែសម្រួល ឧបសម្ព័ន្ធ ១ លេខរៀងទី ៩ និង ឧបសម្ព័ន្ធ ៤ ប្រភេទបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តិ និង បណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិកនៃប្រកាសលេខ ២៨ កយ ប្រក.០៧ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្ដីពីប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្ដី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្ដឹង ដូចខាងក្រោម៖

**ឧបសម្ព័ន្ធ ១ ថ្មី លេខរៀងទី ៩**

| | | | |
|---|---|---|---|
| ៩ | ពាក្យសុំឱ្យផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ | ៣៦៦, ៣៦៧, និង ៣៦៩ | ៥ ០០០ |

**ឧបសម្ព័ន្ធ ៤ ថ្មី ប្រភេទបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តិ**

| | | | |
|---|---|---|---|
| ១១ | ការទាមទារអោយរំលាយ ឬ ទាមទារអោយបន្ថយថ្លៃឈ្នួល ក្នុងករណីដែលចំណូលថយចុះ ដោយសារការបាត់បង់ ឬ វិនាស វត្ថុជួលមួយភាគ (មាត្រា ៦០៦ និង មាត្រា ៦០៧ នៃក្រមរដ្ឋប្បវេណី ) | ១. ចំនួនថ្លៃឈ្នួលដែលដើមចោទអះអាងថាបានកាត់បន្ថយ x (កំឡុងពេលពីដើមដំបូងនៃការកាត់បន្ថយដល់ពេលដាក់ពាក្យបណ្ដឹង) + ៦ ខែ<br>២. ប្រសិនបើដើមចោទធ្វើសេចក្ដីបញ្ជាក់ដំបូងថា១/២នៃតម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាទាបជាងចំនួនដែលគណនាតាមរបៀបទី១ខាងលើត្រូវយក១/២នៃតម្លៃអចលនវត្ថុ | ដោយយោងទៅលើការសន្មត់ថា ៦ ខែ គឺជាអំឡុងពេលមធ្យមសំរាប់ធ្វើការជំនុំជម្រះរឿងក្ដី |
| ១២ | បណ្ដឹងទាមទារអោយបញ្ជាក់ពីសិទ្ធិជួល | ចំនួនថ្លៃឈ្នួល x ៦ ខែ | ដោយយោងទៅលើការសន្មត់ថា ៦ ខែ គឺជាអំឡុងពេលមធ្យម សំរាប់ធ្វើការជំនុំជម្រះ រឿងក្ដី |

**ឧបសម្ព័ន្ធ ៤ ថ្មី ប្រភេទបណ្ដឹងទាមទារឲ្យផ្ដល់តាវកាលិក**

| | | | |
|---|---|---|---|
| ៦ | ការប្រគល់លិខិតប្រគល់សិទ្ធិ | ១.ក្នុងករណីដែលការទាមទារផ្អែកទៅលើកម្មសិទ្ធិ ឬ ការបញ្ចប់កិច្ចសន្យា ត្រូវយក ១/២ នៃតម្លៃនៃសិទ្ធិដែលមានចែងនៅក្នុងលិខិតប្រគល់សិទ្ធិ។ | ចំពោះការធ្វើសេចក្ដីបញ្ជាក់ដំបូង តុលាការត្រូវបង្គាប់ឱ្យភាគីដាក់នូវលិខិតបញ្ជាក់ទៅ |

| | | | |
|---|---|---|---|
| | | ២. ក្នុងករណីដែលការទាមទារផ្អែកទៅលើសិទ្ធិកាន់កាប់ត្រូវ យក ១/៣ នៃតម្លៃសិទ្ធិដែលមានចែងនៅក្នុងលិខិតប្រគល់សិទ្ធិ។ | តាមលក្ខណៈនៃរឿងក្តី។ ប្រសិនបើការដាក់លិខិតបញ្ជាក់មានការលំបាក សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយការបង្ហាញសេចក្តីបញ្ជាក់ដំបូងរបស់ដើមចោទ។ |

**ប្រការ ២** : ប្រកាសនេះ នឹងយកទៅអនុវត្តក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយពីថ្ងៃចុះហត្ថលេខា។ ៤០៧ 5

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០០៩

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍនា

**ចម្លងជូន៖**

- តុលាការគ្រប់ជាន់ថ្នាក់

"ដើម្បីអនុវត្ត"

- មហាអយ្យការអមតុលាការកំពូល
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមសាលាដំបូងខេត្ត-រាជធានី
- តុលាការយោធា និង អយ្យការអមតុលាការយោធា
- គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

"ដើម្បីជ្រាប"

ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ ១ ថ្មី**

| | ប្រភេទនៃពាក្យសុំ ដែលតម្រូវឱ្យបង់ពន្ធ | មាត្រាយោង | តម្លៃពន្ធ (រៀល) |
|---|---|---|---|
| ១ | ពាក្យប្តឹងជិតចិត្ត | ២៨ | ៥ ០០០ |
| ២ | ពាក្យសុំចូលរួមជួយអន្តរាគមន៍ ពាក្យសុំចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង | ៤៣ ៤៩ | ៥ ០០០ |
| ៣ | ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង | ១៦៤<br>កថាខណ្ឌ ២ | ៥ ០០០ |
| ៤ | ពាក្យប្តឹងទាស់ | ២០៤ | ៥ ០០០ |
| ៥ | ពាក្យប្តឹងជំទាស់ | ៣០១ | ៥ ០០០ |
| ៦ | ពាក្យសុំតវ៉ាចំពោះការអនុវត្ត | ៣៨៤ | ៥ ០០០ |
| ៧ | ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ | ៣៥៣ | ៥ ០០០ |
| ៨ | ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត | ៣៦២ | ៥ ០០០ |
| ៩ | ពាក្យសុំឱ្យផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ | ៣៦៦, ៣៦៧, និង ៣៦៩ | ៥ ០០០ |
| ១០ | ពាក្យសុំឱ្យដីកាសម្រេចបង្គាប់ឱ្យប្រគល់ | ៣៩០ ៤៥០ ៤៥៩ ៤៨៣ | ៥ ០០០ |
| ១១ | ពាក្យសុំទាមទារឱ្យចែកចំណែក | ៣៩៤ ៤០៩ ៤២៦ | ៥ ០០០ |
| ១២ | ពាក្យសុំការចាត់ចែងការរក្សាការពារ | ៤២៩ | ៥ ០០០ |
| ១៣ | ពាក្យសុំឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា | ៤៦១ | ៥ ០០០ |
| ១៤ | ពាក្យសុំការអនុញ្ញាតឱ្យនាវាធ្វើដំណើរ | ៤៦២ | ៥ ០០០ |
| ១៥ | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ | ៥៥០ | ៥ ០០០ |
| ១៦ | ពាក្យសុំឱ្យផ្អាកការអនុវត្តរក្សាការពារ | ៥៥១ | ៥ ០០០ |
| ១៧ | ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ | ៥៥៧ ៥៥៨ ៥៥៩ | ៥ ០០០ |

**ឧបសម្ព័ន្ធ ២**

| | សកម្មភាពដែលតម្រូវឱ្យបង់ពន្ធ | មាត្រាយោង | តម្លៃពន្ធ (រៀល) |
|---|---|---|---|
| ១ | ការទាមទារមើល ឬការទាមទារថតចម្លងសំណុំរឿង។ ប៉ុន្តែក្នុងករណី ដែលភាគីទាមទារនៅពេលដែលរឿងក្តីកំពុងចាត់ការមិនតម្រូវឱ្យបង់ទេ។ ចំពោះការចំណាយក្នុងការថតចម្លងឯកសារសំណុំរឿង ជាបន្ទុករបស់អ្នកទាមទារ។ | មាត្រា ២៥៨ ៣៧៨ ៥៣៨ | ៥ ០០០<br>ក្នុងមួយដង |
| ២ | ការប្រគល់ឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមាន | មាត្រា ២៥៨ ៣៧៨ | ៥ ០០០ |

| | | | |
|---|---|---|---|
| | សេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង | ៥៣៨ | ក្នុងឯកសារ<br>មួយឈុត |
| ៣ | ការប្រគល់នូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្ដីសម្រេច | មាត្រា ២៥៨ ៣៧៨<br>និង ៣៥៥<br>កថាខណ្ឌ ២ ជាអាទិ៍ | ៥ ០០០<br>ក្នុងឯកសារ<br>មួយឈុត |
| ៤ | ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត | មាត្រា ៣៥៥<br>ជាអាទិ៍ | ៥ ០០០ |

**ឧបសម្ព័ន្ធ ៣**

| | **ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធដាក់ពាក្យសុំ** | **ចំនួនសោហ៊ុយក្នុងមួយថ្ងៃ/យប់ (រៀល)** |
|---|---|---|
| ១ | សោហ៊ុយធ្វើដំណើរសម្រាប់ចៅក្រម | ៤៦.០០០ រៀល +ថ្លៃធ្វើដំណើរជាមធ្យម តាម មធ្យោបាយធ្វើដំណើរសាធារណៈឆ្ពោះទៅកាន់គោលដៅ |
| ២ | សោហ៊ុយធ្វើដំណើរសម្រាប់ក្រឡាបញ្ជី | ២៣.០០០ រៀល +ថ្លៃធ្វើដំណើរជាមធ្យម តាមមធ្យោបាយធ្វើដំណើរសាធារណៈ ឆ្ពោះទៅកាន់គោលដៅ |
| ៣ | សោហ៊ុយស្នាក់នៅសម្រាប់ចៅក្រម | ៨០.០០០ រៀល |
| ៤ | សោហ៊ុយស្នាក់នៅសម្រាប់ក្រឡាបញ្ជី | ៤០.០០០ រៀល |
| ៥ | សោហ៊ុយបញ្ជូនឯកសារតាមលិខិតអនុសិដ្ឋ | ចំនួនដូចគ្នានឹងថ្លៃចំណាយក្នុងការបញ្ជូនឯកសារជាសំបុត្រអនុសិដ្ឋ ដោយមានរបាយការណ៍បញ្ជាក់ការដល់នៃភណ្ឌិការ (កញ្ចប់ផ្ញើ តាមប្រៃសណីយ៍) |
| | កំណត់សំគាល់ ៖ សោហ៊ុយស្នាក់នៅអាចផ្ដល់ជូន តែក្នុងករណីដែលចំងាយធ្វើដំណើរលើសពី ៤០ គីឡូម៉ែត្រ ប៉ុណ្ណោះ លើកលែងតែ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និង ខេត្តបន្ទាយមានជ័យ ដែលសោហ៊ុយស្នាក់នៅអាចផ្ដល់ជូន ក្នុងករណីដែលចំងាយធ្វើដំណើរលើសពី ៣០ គីឡូម៉ែត្រ។ | |

**ឧបសម្ព័ន្ធ ៤ ថ្មី**

កំណត់សំគាល់: ចំពោះរាល់ការគណនាតម្លៃនៃវត្ថុត្រូវធ្វើឡើងដោយផ្អែកលើសេចក្ដីបញ្ជាក់ដំបូង។ សេចក្ដីបញ្ជាក់ដំបូងអាចធ្វើឡើងដោយការបង្ហាញបង្កាន់ដៃ ឬ ដោយឯកសារកិច្ចសន្យា ជាអាទិ៍។ នៅក្នុងករណី ដែលពុំអាចរកឯកសារទាំងនោះបានទេ តម្លៃនៃវត្ថុត្រូវកំណត់តាមសេចក្ដីបញ្ជាក់ដំបូងរបស់ដើមចោទ។

**តារាងគណនាតម្លៃកម្មវត្ថុនៃបណ្ដឹង**

| | ប្រភេទនៃបណ្ដឹង | វិធីគណនា | សេចក្ដីយោង |
|---|---|---|---|
| | **បណ្ដឹងទាមទារអោយបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តិ** | | |
| ១ | សិទ្ធិលើកម្មសិទ្ធិ និង ភោគៈ | ទម្លៃសរុបនៃវត្ថុ | |
| ២ | សិទ្ធិកាន់កាប់ | ១/៣ នៃតម្លៃវត្ថុ | |
| ៣ | សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ | ១. ១/២ នៃតម្លៃវត្ថុដែលជាកម្មវត្ថុ<br>២. ចំពោះសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុដែល ពាក់ព័ន្ធត្រឹមផ្នែកដែលសិទ្ធិអាស្រ័យនៅត្រូវបានទទួលស្គាល់ | |
| ៤ | សេវភាព | ១/៣ នៃតម្លៃ ដីបម្រើ ឬ ដីប្រើ | ការជ្រើសរើសយកតម្លៃដីប្រើ ឬតម្លៃដីបម្រើ ដើម្បីធ្វើការគណនាតម្លៃកម្មវត្ថុនៃបណ្ដឹងគឺ អាស្រ័យលើដើមចោទ។ |
| ៥ | សិទ្ធិប្រាតិភោគប្រត្យក្ស | ចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។ ប្រសិន បើសិទ្ធិលើបំណុល ដែលត្រូវបានធានាមានតម្លៃលើសពី តម្លៃវត្ថុដែលដាក់ ដើម្បីធានាកាតព្វកិច្ច គឺត្រូវយកតម្លៃ វត្ថុនោះ ។ | ១. ចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវគណនាទៅតាមចំនួននៃប្រាក់ដើម ។<br>២. ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ដែលមិនទាន់បានកំណត់ជាស្ថាពរ និងការបញ្ចាំ ដើម្បីធានាបំណុលអណ្ដែត ត្រូវយកចំនួនអតិបរមាមកធ្វើជាមូលដ្ឋាន ។<br>៣. ចំនួននៃសិទ្ធិលើបំណុលត្រូវសម្រេច ទៅតាម ការចុះបញ្ជី ឬ តាមកិច្ចសន្យា ។ |

| | | | |
|---|---|---|---|
| | | | ៤. បើទោះជាមានប្រាតិភោគមួយផ្សេងទៀតមានអត្ថិភាពមុនក៏ដោយ ក៏ចំនួននៃតម្លៃមិន ប្រែប្រួលដែរ ។ |
| ៦ | ទំហំនៃអានុភាពហ៊ីប៉ូតែក (ម.៨៥៦ នៃក្រមរដ្ឋប្បវេណី) | តម្លៃនៃវត្ថុភ្ជាប់ | |
| ៧ | សិទ្ធិប្រត្យក្សដែលបង្កើតឡើងដោយច្បាប់ដោយឡែក | -ករណីដែលអាចធ្វើអនុប្បទានបាន ត្រូវយកតម្លៃនៃផល ប្រយោជន៍ដែលបានមកពីអនុប្បទាន<br>-ករណីដែលមិនអាចធ្វើអនុប្បទានទេ ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល | |
| ៨ | បណ្តឹងទាមទារឱ្យបញ្ជាក់ពីនត្ថិភាពនៃកាតព្វកិច្ចជាប្រាក់ដោយមានការបញ្ជាក់ ពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចនោះ | ចំនួននៃកាតព្វកិច្ចជាប្រាក់នោះ ។ | |
| ៩ | បណ្តឹងទាមទារឱ្យបញ្ជាក់ពីនត្ថិភាពនៃកាតព្វកិច្ចជាប្រាក់ដោយគ្មានការបញ្ជាក់ច្បាស់ពីចំនួនទឹកប្រាក់នៃកាតព្វកិច្ច | ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល | បើទោះជាមានភាគីប៉ុន្មាននាក់ក៏ដោយ ។ |
| ១០ | បណ្តឹងទាមទារឱ្យបញ្ជាក់ពីភាពត្រឹមត្រូវនៃការធ្វើឯកសារ | ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល | ១. តម្លៃនៃវត្ថុត្រូវគណនាដោយយោងទៅតាម ចំនួនឯកសារដោយមិនគិតអំពីខ្លឹមសារនៃឯកសារទេ។<br>២. ខ្លឹមសារនៃឯកសារអាចជាទឹកប្រាក់ ឬមិនមែន ជាទឹកប្រាក់។ |
| ១១ | ការទាមទារអោយរំលោយ ឬ ទាមទារអោយបន្ថយថ្លៃឈ្នួល ក្នុងករណីដែលចំណូលថយចុះ | ១. ចំនួនថ្លៃឈ្នួលដែលដើមចោទអះអាងថាបានកាត់បន្ថយ x (កំឡុងពេលពីដើមដំបូងនៃការកាត់បន្ថយដល់ពេលដាក់ពាក្យបណ្តឹង ) + ៦ ខែ | ដោយយោងទៅលើ ការសន្មត់ថា ៦ ខែ គឺជាអំឡុងពេលមធ្យមសំរាប់ធ្វើការ ជំនុំជម្រះរឿងក្តី |

| | | | |
|---|---|---|---|
| | ដោយសារការបាត់បង់ ឬ វិនាស វត្ថុជួលមួយភាគ (មាត្រា ៦០៦ និង ៦០៧ នៃក្រមរដ្ឋប្បវេណី ) | ២. ប្រសិនបើដើមចោទធ្វើសេចក្តីបញ្ជាក់ដំបូងថា១/២នៃតម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាទាបជាងចំនួនដែលគណនាតាមរបៀបទី១ខាងលើត្រូវយក១/២នៃតម្លៃអចលនវត្ថុ | |
| ១២ | បណ្តឹងទាមទារអោយបញ្ជាក់ពីសិទ្ធិជួល | ចំនួនថ្លៃឈ្នួល x ៦ ខែ | ដោយយោងទៅលើការ សន្មត់ថា ៦ ខែ គឺជា អំឡុងពេលមធ្យម សំរាប់ធ្វើការជំនុំជម្រះ រឿងក្តី |
| | **បណ្តឹងទាមទារឱ្យបង្កើត ផ្លាស់ប្តូរ ឬ រំលត់ ទំនាក់ទំនងគតិយុត្ត** | | |
| ១ | ការទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ (ម. ២១២ នៃក្រមរដ្ឋប្បវេណី) | ១/៣ នៃតម្លៃចំណែកកម្មសិទ្ធិអវិភាគរបស់ដើមចោទ | មធ្យោបាយដែលអាចត្រូវបានស្នើឡើងដោយ ដើមចោទ មិនត្រូវយកមកពិចារណាទេ ។ |
| ២ | ការទាមទារឱ្យលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ (ម. ៤២៨ ក្រមរដ្ឋប្បវេណី) | ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលដើមចោទមាន ។ ប៉ុន្តែ ប្រសិនបើដើមចោទ ធ្វើសេចក្តីបញ្ជាក់ដំបូងថា តម្លៃនៃវត្ថុដែល ខ្លួនបានទទួលជាតាវកាលិកនៃអំពើដែលនាំឱ្យ ខូចខាតផលប្រយោជន៍ទាបជាងសិទ្ធិលើបំណុល គឺត្រូវយកតម្លៃនៃវត្ថុនោះ។ | តុលាការអាចបង្គាប់ឱ្យដើមចោទធ្វើសេចក្តីបញ្ជាក់ដំបូងអំពីតម្លៃនៃអំពើដែលនាំឱ្យខូចខាតផល ប្រយោជន៍។ |
| ៣ | ការទាមទារឱ្យរំលាយ ឬ ទាមទារឱ្យបន្ថយថ្លៃឈ្នួលក្នុងករណីដែលចំណូលថយចុះដោយសារការបាត់បង់ឬវិនាស វត្ថុជួលមួយភាគ (ម. ៦០៦ និង ម. ៦០៧ នៃ ក្រមរដ្ឋប្បវេណី) | ១. ចំនួនថ្លៃឈ្នួលដែលដើមចោទអះអាងថាបានកាត់បន្ថយ x [អំឡុងពេលពីដើមដំបូងនៃការកាត់បន្ថយដល់ពេលដាក់ ពាក្យបណ្តឹង + ៦ ខែ]<br>២. ប្រសិនបើដើមចោទធ្វើសេចក្តីបញ្ជាក់ដំបូងថា ១/២ នៃ តម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាទាបជាងចំនួន ដែលគណនាតាម | ដោយយោងទៅលើការសន្មត់ថា ០៦ ខែ គឺជា អំឡុងពេលមធ្យម សម្រាប់ធ្វើការជំនុំជម្រះរឿងក្តី |

| | | | |
|---|---|---|---|
| | | របៀបទី ១ ខាងលើ ត្រូវយក១/២នៃតម្លៃនៃអចលនវត្ថុ | |
| | **បណ្តឹងទាមទារអោយផ្តល់តាមការពិត** | | |
| ១ | ការសងប្រាក់ដែលមានកំណត់ចំនួនច្បាស់លាស់ | ចំនួនទឹកប្រាក់ដែលដើមចោទទាមទារឱ្យចុងចម្លើយសង។ | |
| ២ | ការសងប្រាក់ដែលបានធ្វើឡើងជាបន្តបន្ទាប់ ឬច្រើនដងតាមពេលវេលា | ត្រូវគណនាដូចខាងក្រោម ៖<br>ចំនួនទឹកប្រាក់ដែលទាមទារនៅពេលដាក់ពាក្យបណ្តឹង+ [ប្រាក់សងប្រចាំខែ x ១២ ខែ] ។<br>ប្រសិនបើកាល បរិច្ឆេទសងស្ថាពរនឹងមកដល់ក្នុងអំឡុងពេល ១ ឆ្នាំ ត្រូវ យកចំនួនទឹកប្រាក់សរុបនៃការទាមទារ ។ | ១. ដោយយោងទៅលើការសន្មត់ថា ១២ ខែ គឺ ជាអំឡុងពេលមធ្យមសម្រាប់ធ្វើការ ជំនុំជម្រះ រឿងក្តី។<br>២. ចំពោះការបង់ ថ្លៃឈ្នួលដែលកើនឡើង ក៏ត្រូវ គណនាតាមរបៀបដូចគ្នានេះដែរ។ |
| ៣ | ការប្រគល់ចលនវត្ថុ ឬ អចលនវត្ថុជាអាទិ៍ | - បើផ្អែកទៅលើកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា ឬការបញ្ចប់កិច្ចសន្យា ត្រូវយក ១/២ នៃតម្លៃវត្ថុ។<br>- បើផ្អែកទៅលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ។ | ភោគីនៃអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិ កាន់កាប់ត្រូវចាត់ទុកថាជាកម្មសិទ្ធិករចំពោះការ អនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។ |
| ៤ | ការទាមទារឱ្យបញ្ឈប់ ឬ បង្ការជាមុននូវការរារាំងការអនុវត្តសិទ្ធិ | - បើផ្អែកទៅលើកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃ វត្ថុ។<br>- បើផ្អែកទៅលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ | ភោគីនៃអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិ កាន់កាប់ត្រូវចាត់ទុកថាជាកម្មសិទ្ធិករចំពោះការ អនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។ |

| | | | |
|---|---|---|---|
| ៥ | ការប្រគល់ឯកសារដែលត្រូវប្រើប្រាស់ជា មធ្យោបាយបញ្ជាក់ | ថ្លៃចាំបាច់ដើម្បីចេញឯកសារម្តងទៀត ឬ សម្រាប់ធ្វើឯកសារ ម្តងទៀត។ | ១. ក្នុងករណីដែលឯកសារធ្វើដោយបុគ្គលឯកជន ត្រូវយកថ្លៃសម្រាប់ចេញឯកសារថ្មី<br>២. សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងតាមរយៈ លិខិតបញ្ជាក់ដែលចេញដោយតតិយជន។ ក្នុងករណីដែលមានការលំបាកក្នុងការធ្វើឯកសារ នេះ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយការ បង្ហាញសេចក្តីបញ្ជាក់ដំបូងរបស់ដើមចោទ។ |
| ៦ | ការប្រគល់លិខិតប្រគល់សិទ្ធិ | ១.ក្នុងករណីដែលការទាមទារផ្អែកទៅលើកម្មសិទ្ធិ ឬ ការបញ្ចប់ កិច្ចសន្យា ត្រូវយក ១/២ នៃតម្លៃនៃសិទ្ធិដែលមានចែងនៅក្នុងលិខិតប្រគល់សិទ្ធិ។<br>២. ក្នុងករណីដែលការទាមទារផ្អែកទៅលើសិទ្ធិកាន់កាប់ត្រូវ យក ១/៣ នៃតម្លៃសិទ្ធិ ដែលមានចែងនៅក្នុងលិខិតប្រគល់សិទ្ធិ។ | ចំពោះការធ្វើសេចក្តីបញ្ជាក់ដំបូង តុលាការ ត្រូវ បង្គាប់ឱ្យភាគីដាក់នូវលិខិតបញ្ជាក់ ទៅតាម លក្ខណៈនៃរឿងក្តី។ ប្រសិនបើការដាក់លិខិតបញ្ជាក់មានការលំបាក សេចក្តីបញ្ជាក់ដំបូងត្រូវ ធ្វើឡើងដោយការបង្ហាញសេចក្តីបញ្ជាក់ដំបូង របស់ដើមចោទ។ |
| ៧ | ការប្រគល់ឯកសារក្រៅពីឯកសារដែល ត្រូវប្រើដើម្បីជាមធ្យោបាយបញ្ជាក់ | ១. ក្នុងករណីដែលការទាមទារផ្អែកលើកម្មសិទ្ធិ ត្រូវយក ១/២ នៃតម្លៃឯកសារ។<br>២. ក្នុងករណីដែលការទាមទារផ្អែកទៅលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃឯកសារ។ | ១.សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយបង្ហាញលិខិតបញ្ជាក់ដែលចេញដោយតតិយជន ប្រសិន បើលិខិតនោះ មានតម្លៃទីផ្សារ។<br>២. ប្រសិនបើមានការលំបាកក្នុងការធ្វើឯកសារ ដែលចេញដោយតតិយជន ឬប្រសិនបើមិនមាន តម្លៃទីផ្សារទេ ត្រូវយកតម្លៃដែលដើមចោទបាន ធ្វើសេចក្តីបញ្ជាក់ដំបូង។ |
| ៨ | ការទាមទារឱ្យផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈ (ម. ៧៥៧ នៃក្រមរដ្ឋប្បវេណី) | ១. ក្នុងករណីដែលសេចក្តីសុំអភ័យទោសត្រូវចុះផ្សាយ តាមរយៈសារព័ត៌មាន ឬទស្សនាវដ្តី ត្រូវយកតម្លៃចុះផ្សាយ។ | ១.សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយតារាង រាយតម្លៃ ឬដោយលិខិតបញ្ជាក់ ប្រសិនបើ មានការកំណត់ថ្លៃចុះផ្សាយរួចហើយ។ |

| | | | |
|---|---|---|---|
| | | ២. ក្នុងករណីដែលសេចក្តីសុំអភ័យទោស ត្រូវផ្សព្វផ្សាយតាម រយៈបញ្ជូនដំណឹង ឬ មធ្យោបាយផ្សព្វផ្សាយផ្ទៃក្នុង ត្រូវយកតម្លៃស្មុំជូនដំណឹង។ | ២. ប្រសិនបើពុំមានការកំណត់ថ្លៃច្បាស់លាស់ទេ ត្រូវយកចំនួនទឹកប្រាក់នៃការចំណាយលើការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈ ដែលដើមចោទបានអះអាងដោយការធ្វើសេចក្តីបញ្ជាក់ដំបូង។ |
| ៩ | ការទាមទារប្រើដីដែលជាប់គ្នា (ម. ១៤៣ នៃក្រមរដ្ឋប្បវេណី) | ១/៣ នៃតម្លៃដីជាប់គ្នាដែលដើមចោទស្នើសុំប្រើ។ | |
| ១០ | ការទាមទារសុំឆ្លងកាត់ដីអ្នកជិតខាង (ករណីដីបិទជិត) (ម. ១៤៤ នៃក្រមរដ្ឋប្បវេណី) | ១/៣ នៃតម្លៃដីដែលដើមចោទសុំជាផ្លូវដើរចេញចូល ។ | |
| ១១ | ការប្តឹងទាមទារធ្វើផ្លូវទឹកដើម្បីស្រោចស្រព (ម.១៤៨ នៃក្រមរដ្ឋប្បវេណី) ការប្តឹងទាមទារបង្ហូរចោលទឹក ស្រោចស្រព(ម.១៤៩ នៃក្រមរដ្ឋប្បវេណី) ការប្តឹងទាមទារបង្ហូរទឹកចោលនៃកម្មសិទ្ធិករនៃដីលិចទឹក(ម. ១៥០ នៃក្រមរដ្ឋប្បវេណី) | ១/៣ នៃតម្លៃដីដែលចាំបាច់សម្រាប់បង្ហូរទឹក ។ | |
| ១២ | ការប្តឹងទាមទារលើកទំនប់ | ១/៣ នៃតម្លៃដីដែលសម្រាប់ធ្វើសិល្បៈការចាំបាច់ដើម្បីយកទឹក ។ | |
| ១៣ | ការប្តឹងទាមទារកាប់ដើមឈើដែលដុះឆ្លងព្រំដី (ម. ១៤២ នៃក្រមរដ្ឋប្បវេណី) | ១/៣ នៃតម្លៃដីត្រឹមទំហំដែលមែកឈើឆ្លងចូល ។ | |
| ១៤ | ការទាមទារឱ្យដាក់របាំងបាំងនៅបង្អួច | ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល ។ | |

| | | | |
|---|---|---|---|
| | (ម. ១៥៣ នៃក្រមរដ្ឋប្បវេណី) | | |
| ១៥ | ការទាមទារធ្វើសកម្មភាពថែរក្សារបស់ភតិបតី (ម. ៦០៣ នៃក្រមរដ្ឋប្បវេណី) | ១/២ នៃតថ្លៃជួសជុល ។ | ការប៉ាន់ប្រមាណថ្លៃជួសជុល ត្រូវធ្វើឡើង តាមរយៈវិក័យប័ត្រនៃការប៉ាន់ប្រមាណ។ |
| ១៦ | ការទាមទារឱ្យហាមកុំឱ្យចូល | -បើផ្អែកទៅលើសិទ្ធិប្រត្យក្សក្រៅពីសិទ្ធិកាន់កាប់ ត្រូវយក ១/២ នៃតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ។<br>-ប្រសិនបើផ្អែកលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃ អចលនវត្ថុ ដែលជាកម្មវត្ថុ។<br>-ប្រសិនបើផ្អែកទៅលើសិទ្ធិផ្សេងទៀតក្រៅពីសិទ្ធិទាំងពីរខាង លើ ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល។ | |
| | **ការចុះបញ្ជីដីធ្លី** | | |
| ១ | ការផ្ទេរកម្មសិទ្ធិ | តម្លៃនៃដី | |
| ២ | ការចុះបញ្ជី ការធ្វើអនុប្បទាន ឬ ការលុបចោលនូវការចុះបញ្ជីចំពោះការជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ | ១/២ នៃតម្លៃដី ។ | |
| ៣ | ការចុះបញ្ជី ឬ ការរំលត់សេវភាព | ១/៣ នៃតម្លៃដីបម្រើ ឬ នៃតម្លៃនៃដីប្រើ ។ | ការជ្រើសរើសយកតម្លៃនៃដីបម្រើ ឬ ដីប្រើដើម្បី ធ្វើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងគឺអាស្រ័យ ទៅលើដើមចោទ ។ |
| ៤ | ការចុះបញ្ជីសិទ្ធិប្រាតិភោគ | តម្លៃនៃសិទ្ធិលើបំណុល ដែលមានប្រាតិភោគ ។ ប្រសិនបើដី មានតម្លៃទាបជាងសិទ្ធិលើបំណុល | តម្លៃនៃសិទ្ធិលើបំណុល ត្រូវគណនាដោយផ្អែកតែ លើប្រាក់ដើមប៉ុណ្ណោះ ។ |

J15

| | | | |
|---|---|---|---|
| | | គឺត្រូវយកតម្លៃ ដី ។ | |
| | **ញាតិ ឬ សន្តតិកម្ម** | | |
| ១ | រឿងក្តីដែលពាក់ព័ន្ធនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងឪពុក-ម្តាយ និង កូន | ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល ។ | |
| ២ | ការទាមទារនូវសំណងដែលភ្ជាប់ទៅនឹង បណ្តឹងក្នុងចំណុច ១ | ចំនួនដែលខ្ពស់ជាងគេ ដែលអាចជា ៥.៥០០.០០០ រៀល ឬ ចំនួននៃប្រាក់សំណង។ | |
| ៣ | ពាក្យសុំឱ្យបែងចែកទ្រព្យសម្បត្តិ ឬ ការកំណត់ការចាត់ចែងទាក់ទងទៅនឹង ការបីបាច់ថែរក្សាកូន ដែលដាក់បញ្ចូល រួមគ្នា នៅក្នុងបណ្តឹងសុំលែងលះ ឬ សុំមោឃៈភាពអាពាហ៍ពិពាហ៍ | មិនតម្រូវឱ្យបង់ពន្ធទេ ។ | |
| ៤ | ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម (ម. ១៣០១ នៃក្រមរដ្ឋប្បវេណី) | -បើជាសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃនៃវត្ថុទាំងមូល ។<br>-បើជាសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ ។<br>-បើជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃ វត្ថុ ។<br>-បើជាសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើដោយយោងទៅលើទ្រព្យសន្តតិកម្ម ។ | |
| ៥ | ការទាមទារឱ្យបញ្ជាក់ពីមោឃៈភាពនៃ | ត្រូវធ្វើការគណនាដោយផ្អែកទៅតាមខ្លឹមសារ | |

J15

| | | | |
|---|---|---|---|
| | មតកសាសន៍ | នៃមរតកសាសន៍ ដូចខាងក្រោម ៖<br>១. ចំពោះការចាត់ចែងទ្រព្យ (មាត្រា ១១៨៥) គឺ តម្លៃទ្រព្យ ដែលចាត់ចែង x ចំណែកមតិកតាមច្បាប់របស់ដើមចោទ ។<br>២. ការផ្ដាច់មតិកពីសន្តតិជន (មាត្រា ១១៥១) គឺ តម្លៃសរុប នៃមរតក x ចំណែកមរតកតាមច្បាប់របស់ដើមចោទ ។<br>៣. ចំពោះការកំណត់ចំណែកមរតក ឬ ការកំណត់នូវវិធីបែង ចែកមរតក (មាត្រា ១១៨២ និង ១១៨៣) គឺ [តម្លៃនៃចំណែកមរតករបស់ដើមចោទដែលកំណត់នៅក្នុងមតក សាសន៍ + តម្លៃនៃចំណែកមរតករបស់ចុងចម្លើយនៅក្នុងមតកសាសន៍ ] × ចំណែកមរតកតាមច្បាប់របស់ដើមចោទ / [ចំណែកមរតក តាមច្បាប់ របស់ដើមចោទ និង ចុងចម្លើយ]-តម្លៃនៃចំណែកមរតក ដែលមានចែងនៅក្នុងមតកសាសន៍ ។<br>៤. ចំពោះការហាមឃាត់មិនឱ្យបែងចែក (មាត្រា ១១៨៣) គឺតម្លៃ សរុបនៃមរតក x ៥% x អំឡុងពេលហាមឃាត់ xចំណែកតាមច្បាប់របស់ដើមចោទ ។<br>៥. ចំពោះការកំណត់នូវវិធីកាត់បន្ថយអច្ច័យទាន | |

| | | | |
|---|---|---|---|
| | | (មាត្រា ១២៣៧ ចំណុច ៤) គឺ ចំនួននៃទ្រព្យដែលបានកាត់បន្ថយ ដោយផ្អែកលើវិធីដែលបានកំណត់-ចំនួននៃទ្រព្យដែលបានបន្ថយ ដោយផ្អែកលើបញ្ញត្តិស្តីពីការកាត់បន្ថយអច្ច័យទាន (មាត្រា ១២៣៧) ។<br>៦. ចំពោះសិទ្ធិដែលមិនទាក់ទងទៅនឹងទ្រព្យសម្បត្តិ ដូចជា ការទាមទារឱ្យទទួលស្គាល់បញ្ហាដែលទាក់ទងទៅនឹង អាណាព្យាបាលទូទៅ បញ្ហាការប្រគល់អាណត្តិឱ្យតតិយជន កំណត់ពីវិធីបែងចែក (មាត្រា ១១៨៣) ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១១៨៦) ត្រូវចាត់ទុក ថាមានចំនួន ៥.៥០០.០០០ រៀល ។ | |
| ៦ | ការទាមទារឱ្យបញ្ជាក់ពីមោឃៈភាពនៃការបោះបង់សន្តតិកម្ម | តម្លៃសរុបនៃមរតក xចំណែកមតិកតាមច្បាប់របស់ដើមចោទ | |
| ៧ | ការទាមទារឱ្យបញ្ជាក់ពីមោឃៈភាពនៃកិច្ចសន្យាបែងចែកមរតក | តម្លៃសរុបនៃសន្តតិកម្ម x ចំណែកតាមច្បាប់របស់ដើមចោទ - ចំណែករបស់ដើមចោទដែលមានចែងនៅក្នុងកិច្ចសន្យាបែង ចែកមរតក | |
| ៨ | ការទាមទារឱ្យបង្គ្រប់ភាគបម្រុង | ១.ការទាមទារឱ្យសងជាប្រាក់ ៖<br>ចំនួននៃទឹកប្រាក់ដែលដើម បណ្តឹងទាមទារឱ្យសង ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ ៖ | |

J15

| | | | |
|---|---|---|---|
| | | -ចំពោះសិទ្ធិលើកម្មសិទ្ធិ ៖<br>ត្រូវយកតម្លៃសរុបនៃវត្ថុ ។<br>-ចំពោះសិទ្ធិកាន់កាប់៖ត្រូវយក ១/៣ នៃតម្លៃវត្ថុ ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ៖ ត្រូវយក ១/២ នៃ តម្លៃវត្ថុ ។<br>-ចំពោះសេវភាព ៖ ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើ ដោយផ្អែកទៅលើចំណែកមតិក<br>៣. ការចុះបញ្ជីដីធ្លី ៖ ត្រូវយកតម្លៃដីធ្លីនោះ ។ | |
| | **ការអនុវត្តដោយបង្ខំ** | | |
| ១ | បណ្ដឹងទាមទារឱ្យចេញសាលក្រមអនុវត្ត (ម. ៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) | ១/២ នៃតម្លៃដែលទាមទារនៅក្នុងលិខិតអនុវត្ត ។ | ប្រសិនបើការទាមទារនៅក្នុងលិខិតអនុវត្តនោះ មានកម្មវត្ថុជា ៖<br>១.ការទាមទារឱ្យសងជាប្រាក់ ត្រូវយកចំនួននៃទឹកប្រាក់ដែលដើមចោទទាមទារឱ្យសងមកគិត ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ ៖<br>-ចំពោះសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃសរុបនៃ វត្ថុមកគិត។<br>-ចំពោះសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃ វត្ថុមកគិត ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើមកគិត ដោយផ្អែកទៅលើចំណែក មតិក។<br>៣. ការចុះបញ្ជីដីធ្លី ត្រូវយកតម្លៃដីធ្លីនោះមក គិត ។ |
| ២ | បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត | ១/២ នៃតម្លៃនៃការទាមទារនៅក្នុងលិខិតអនុវត្ត ។ | ប្រសិនបើការទាមទារនៅក្នុងលិខិតអនុវត្តនោះ មានកម្មវត្ថុជា ៖ |

J15

| | | | |
|---|---|---|---|
| | (ម. ៣៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) | | ១.ការទាមទារឱ្យសងជាប្រាក់ ត្រូវយកចំនួននៃ ទឹកប្រាក់ដែលដើមចោទទាមទារឱ្យសងមកគិត ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ ៖<br>-ចំពោះសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃសរុបនៃ វត្ថុមកគិត។<br>-ចំពោះសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃ វត្ថុមកគិត ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើមកគិតដោយផ្អែកទៅលើចំណែក មតិក។<br>៣. ការចុះបញ្ជីដីធ្លី ត្រូវយកតម្លៃដីធ្លីនោះមក គិត ។ |
| ៣ | បណ្ដឹងតវ៉ាចំពោះការទាមទារ<br>(ម.៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) | ត្រូវយក ១/២<br>នៃតម្លៃនៃការទាមទារនៅក្នុងលិខិតអនុវត្តលើកលែង តែក្នុងករណីដូចខាងក្រោម ៖<br>១.ករណីដែលមានគោលបំណងទាមទារឱ្យលុបចោលការអនុវត្ត ជាក់ស្ដែង គឺត្រូវយកវត្ថុដែលបានរឹបអូសមកគិត។<br>២.ករណីដែលមានគោលបំណងទាមទារឱ្យលុបចោលការអនុវត្តដោយផ្អែកលើលិខិតអនុវត្តចំពោះការទាមទារដែលតំរូវឱ្យអនុវត្តតាវកាលិកជាបន្តបន្ទាប់ និងច្រើនដងតាមពេល ហើយប្រសិនបើបណ្ដឹងនោះ ផ្អែកទៅលើសំអាងហេតុ | ប្រសិនបើការទាមទារនៅក្នុងលិខិតអនុវត្តនោះ មានកម្មវត្ថុជា ៖<br>១.ការទាមទារឱ្យសងជាប្រាក់ ត្រូវយកចំនួននៃ ទឹកប្រាក់ដែលដើមចោទទាមទារឱ្យសងមកគិត ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ ៖<br>-ចំពោះសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃសរុបនៃ វត្ថុមកគិត។<br>-ចំពោះសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃ វត្ថុមកគិត ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើមកគិតដោយផ្អែកទៅលើចំណែក មតិក។<br>៣. ការចុះបញ្ជីដីធ្លី ត្រូវយកតម្លៃដីធ្លីនោះមកគិត ។ |



J15

| | | | |
|---|---|---|---|
| | | ថា សិទ្ធិលើ បំណុលមិនមានអត្ថិភាព ឬ មិនបាន កើតឡើងទេ គឺយកចំនួន នៃការទាមទារចាប់ពី ពេល នៃការកើតឡើងនូវសិទ្ធិលើបំណុល រហូត ដល់រយៈពេល ១២ ខែក្រោយពីដាក់ពាក្យ បណ្ដឹង។<br>៣.ប្រសិនបើបណ្ដឹងនោះមានគោលបំណងត្រឹម តែទាមទារ ឱ្យបញ្ឈប់ជាបណ្ដោះអាសន្ននូវ អានុភាពអនុវត្តប៉ុណ្ណោះទេ តម្លៃកម្មវត្ថុនៃបណ្ដឹង ត្រូវគណនាដូចខាងក្រោម ៖<br>ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនៅក្នុងលិខិត អនុវត្ត ×អំឡុង ពេលដែលដើមចោទទាមទារ ឱ្យបញ្ឈប់ × (៥%/ឆ្នាំ) | |
| ៨ | បណ្ដឹងតវ៉ារបស់តតិយជន (ម. ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) | ១. បើសិទ្ធិទប់ស្កាត់ការផ្ទេរ ឬ ការប្រគល់នូវវត្ថុ ដែលជាកម្មវត្ថុ នៃការអនុវត្ត ជាសិទ្ធិក្រៅពីសិទ្ធិ កាន់កាប់ ត្រូវយក ១/២ នៃតម្លៃវត្ថុ។<br>២. បើសិទ្ធិទប់ស្កាត់ការផ្ទេរ ឬ ការប្រគល់នូវវត្ថុ ដែលត្រូវអនុវត្ត ដែលជាសិទ្ធិកាន់កាប់ គឺ ១/៣ ត្រូវយកតម្លៃវត្ថុ។<br>៣. ប្រសិនបើបណ្ដឹងតវ៉ាធ្វើឡើងចំពោះការអនុវត្ត លើចលនវត្ថុ ដែលជាវត្ថុដែលអាចជួញដូរបាន ឬ សិទ្ធិលើបំណុលរបស់ តតិយជន គឺ យកតម្លៃ | តម្លៃកម្មវត្ថុយ៉ាងច្រើនបំផុតគឺត្រឹមចំនួនទឹកប្រាក់ នៃសិទ្ធិលើបំណុល ដែលកំណត់នៅក្នុងលិខិតអនុវត្ត |

J15

| | | | |
|---|---|---|---|
| | | នៃវត្ថុដែលអាចជួញដូរបានដែលត្រូវបាន រឹបអូស ឬ សិទ្ធិលើបំណុលនោះ។ | |
| ៥ | បណ្ដឹងតវ៉ារបស់ម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្ដីតវ៉ា ចំពោះការសរសេរលើតារាង ចែកចំណែក (ម. ៥៩២ និង ម. ៥៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) | ១. បណ្ដឹងតវ៉ាដែលធ្វើឡើងដោយម្ចាស់ណុល ៖ ចំនួននៃការកើនឡើងដោយការកែតម្រូវ ឬ ការលុបចោល និងកែប្រែ នៃតារាងចែកចំណែក។<br>២. បណ្ដឹងតវ៉ាដែលធ្វើឡើងដោយកូនបំណុល ៖ គឺចំនួនសិទ្ធិលើ បំណុល ដែលបានតវ៉ា ដោយមិនគិតដល់ចំនួនដែលលើស។ | |

J15